ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ:១៣៦៥.ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**

**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តកោះកុង**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤។

**យោង** ៖ ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា៖ ចំពោះរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ទាក់ទងដល់ការវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន **០៥** នៅខេត្តព្រះសីហនុ ចំនួន **០១** នៅខេត្តកំពង់ស្ពឺ និងចំនួន **០២** នៅខេត្តកោះកុង រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

I- **ក្រុមហ៊ុន វិមានសិលា អិលធីឌី** (VIMEAN SEILA LTD.)

១ -លុបលិខិតលេខ **៨៦៧ សជណ** ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រីទាក់ទងនឹងក្រុមហ៊ុន **វិមានសិលា អិលធីឌី** និងសិទ្ធិប្រទានលេខ **១៨០.សប្រទ** ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល និងលិខិតលេខ **១៥៥/១០ ក.អ.ក** ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំពោះក្រុមហ៊ុន **វិមានសិលា អិលធីឌី** ដែលមានទីតាំងនៅកោះថ្មី ខេត្តព្រះសីហនុ។

-លុបអនុក្រឹត្យលេខ **៣៤ អនក្រ.បក** ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ ស្ដីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **១២៩ អនក្រ.បក** ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ ស្ដីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៩៨៧ ហិកតា** ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ស្ថិតក្នុងកោះថ្មីនៃតំបន់ឧទ្យានជាតិព្រះសីហនុ **"រាម"** ខេត្តព្រះសីហនុ។

២- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនឧទ្យានជាតិព្រះសីហនុ **"រាម"** ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

៣- ប្រគល់ភារកិច្ចជូនគណៈការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលបានដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

## II- ក្រុមហ៊ុន ស៊ាន ហេង អ៊ិនវេសមេន

១- និរាករណ៍លិខិតលេខ **៦៥៦ សជណ** ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន **ស៊ាន ហេង អ៊ិនវេសមេន** ផ្ទៃដីទំហំ **៩៨៨ ហិកតា** ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ **"រាម"** ។

២- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនឧទ្យានជាតិព្រះសីហនុ **"រាម"** ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

## III- ក្រុមហ៊ុន ស៊ាន ហេង អ៊ិនវេសមេន

១- និរាករណ៍លិខិតលេខ **៨៥ សជណ.កស** ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន **ស៊ាន ហេង អ៊ិនវេសមេន** ផ្ទៃដីទំហំ **៣៥០ ហិកតា** ដែលមានទីតាំងស្ថិតនៅភូមិបឹងត្រាព្រហ្ម សង្កាត់បឹងតាព្រហ្ម ភូមិស្រែចាមលើ សង្កាត់អូរជ្រៅ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិព្រះសីហនុ **"រាម"** ។

២- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនឧទ្យានជាតិព្រះសីហនុ **"រាម"** ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

## IV- ក្រុមហ៊ុន BLUE METRO Co.,LTD

១- និរាករណ៍លិខិតលេខ **៩៩៤ សជណ** ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រីដែលផ្តល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន BLUE METRO Co.,LTD ផ្ទៃដីទំហំ **៣៥០ ហិកតា** ដែលមានទីតាំងស្ថិតនៅតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិព្រះសីហនុ **"រាម"** ។

២- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនឧទ្យានជាតិព្រះសីហនុ **"រាម"** ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

៣- ប្រគល់ភារកិច្ចជូនគណៈការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលបានដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

## V- ក្រុមហ៊ុន ហេង ម៉ុនលាភ ខូអិលធីឌី

១- និរាករណ៍លិខិតលេខ **៧៨៣ សជណ** ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

២- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនឧទ្យានជាតិព្រះសីហនុ **"រាម"** ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

៣- ប្រគល់ភារកិច្ចជូនគណៈការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស ដើម្បីគ្រប់គ្រងផ្ទៃដីដែលបានដកហូតស្របតាមលិខិតបទដ្ឋានជាធរមាន។

## VI- ក្រុមហ៊ុន ស៊ាន់ វឌ្ឍនៈ ខូអិលធីឌី (SUON VATANAK CO.,LTD)

១ -និរាករណ៍លិខិតលេខ **៥៣៤ សជណ** ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានផ្តល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន **ស៊ាន់ វឌ្ឍនៈ ខូអិលធីឌី** ផ្ទៃដីទំហំ **៥៨៥ ហិកតា** និងសិទ្ធិប្រទានលេខ **១៣៩.សប្រទ** ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល។

-លុបអនុក្រឹត្យលេខ **៨៩ អនក្រ.បក** ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **១២៨ អនក្រ.បក** ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៥៨៥ ហិកតា** ស្ថិតក្នុងតំបន់ទ្រនាប់សត្វឆ្លងកាត់រវាងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ **"គិរីរម្យ"** និងឧទ្យានជាតិព្រះមុន្នីវង្ស **"បូកគោ"** ខេត្តកំពង់ស្ពឺ និងខេត្តកោះកុងរបស់រាជរដ្ឋាភិបាល។

២- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ **"គិរីរម្យ"** និងឧទ្យានជាតិព្រះមុន្នីវង្ស **"បូកគោ"** ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

## VII- ក្រុមហ៊ុន ច័ន្ទ រតន៍ គ្រុប

១ -និរាករណ៍លិខិតលេខ **១៤៨ សជណ.កស** ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន **ច័ន្ទ រតន៍ គ្រុប** ផ្ទៃដីទំហំ **៦៣ ហិកតា** ដែលស្ថិតនៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ភូមិសាស្ត្រឃុំជ្រោយស្វាយស្រុកស្រែអំបិល ខេត្តកោះកុង។

-លុបអនុក្រឹត្យលេខ **៣២ អនក្រ.បក** ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ភូមិសាស្ត្រឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ច័ន្ទ រតន៍ គ្រុប** ដើម្បីចិញ្ចឹមក្តាម បង្គារ ត្រី និងចូលរួមក្នុងការអភិរក្សព្រៃកោងកាងតាមតំបន់ឆ្នេរសមុទ្រ។

២- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

VIII- **ក្រុមហ៊ុន ឋានសួគ៌ ចំការត់** ( PARADISE INVESTMENT Co.,Ltd )

១- និរាករណ៍លិខិតលេខ **២៦៤ សជណ** ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រីដែលផ្តល់គោលការណ៍វិនិយោគដល់ក្រុមហ៊ុន **ឋានសួគ៌ ចំការត់** ផ្ទៃដីទំហំ **៩.១៣៧ ហិកតា** ដែលស្ថិតនៅក្នុងតំបន់ឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រខេត្តកោះកុង។

២- ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូនឧទ្យានជាតិបុទុមសាគរ ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**គឹករ៉េត សំរេច**

**ចម្លងជូន៖**
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងធនធានទឹក និងឧតុនិយម
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
-ឯកសារ-កាលប្បវត្តិ